# ព្រះរាជជីវប្រវត្តិសង្ខេប
# ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ
# ព្រះបរមរតនកោដ្ឋ



# SUMMARY BIOGRAPHY
of
His Majesty Preah Bat Samdech Preah NORODOM SIHANOUK
"PREAH BOROM RATANAK KAUDH"




សូមបួងសួង
សូមព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រ
ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី
និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ»
យាងសោយព្រះបរមសុខ
ក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ

# ព្រះរាជជីវប្រវត្តិសង្ខេប
# ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ
# ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី
# និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ»

ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ «ព្រះបរមរតនកោដ្ឋ» ព្រះអង្គប្រសូតនៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ព.ស.២៤៦៥ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ព្រះអង្គជាព្រះរាជបុត្រទោលរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត និងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរតន៍ សិរីវឌ្ឍនា។ ខាងខ្សែព្រះមាតា ព្រះអង្គជាព្រះរាជនត្តារបស់ ព្រះករុណា ព្រះបាទសម្តេច ព្រះមុនីវង្ស និងជាព្រះរាជនត្តាទួត របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម បើរាប់តាមខ្សែព្រះបិតា។

ចាប់ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤០ ព្រះអង្គបានចូលសិក្សានៅសាលាបឋមសិក្សា François Baudoin និងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ។ បន្ទាប់មក ព្រះអង្គបានយាងទៅបន្តការសិក្សានៅវិទ្យាល័យបារាំង សាសលូ ឡូបា (Chasseloup Laubat) នៅទីក្រុងព្រៃនគរ «Saigon» បច្ចុប្បន្នសាលាមធ្យមសិក្សា ឡេ គ្វី ដូន ទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។

លុះដល់ខែមេសា ឆ្នាំ១៩៤១ ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កបានជ្រើសតាំង និងថ្វាយព្រះរាជឋានៈព្រះអង្គជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិ នៅថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំម្សាញ់ ត្រីស័ក ព.ស.២៤៨៤ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១។

នៅឆ្នាំ១៩៤៦ ព្រះអង្គបានយាងបំពេញព្រះរាជទស្សនកិច្ច ជាលើកដំបូងនៅប្រទេសបារាំង តាមការអញ្ជើញរបស់លោកប្រធានាធិបតី Felix Gouin និងបានជួបលោកឧត្តមសេនីយ៍ សាលដឺហ្គោល (Charles de Gaulle) នៅ Colombey។ នៅឆ្នាំ១៩៤៦ និង១៩៤៨ ព្រះអង្គបានបន្តការសិក្សាជាន់ខ្ពស់ នៅសាលាអនុវត្តទ័ពសេះ និងកងទ័ពរថពាសដែកនៅសូមួរ (Saumur) ប្រទេសបារាំង។

ក្នុងឆ្នាំ១៩៤៧ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះអង្គបានទទួលមហាជោគជ័យក្នុងការទាមទារឲ្យព្រះរាជាណាចក្រថៃឡង់ សងមកព្រះរាជាណាចក្រកម្ពុជាវិញ

ជាដាច់ខាតនូវខេត្តខ្មែរ ដែលក្នុងពេលមានចម្បាំងសកលលោកលើកទី ២ ថៃឡង់បានយកពីកម្ពុជាទៅគឺខេត្តបាត់ដំបង សៀមរាប កំពង់ធំ និងស្ទឹងត្រែង។

ឆ្នាំ១៩៤៩ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** បានទាមទារឲ្យប្រទេសបារាំងបញ្ឈប់នូវសន្ធិសញ្ញាអាណាព្យាបាល ដែលបានចុះហត្ថលេខានៅឆ្នាំ១៨៦៣ និងឆ្នាំ ១៨៨៤។ នៅឆ្នាំ១៩៤៩ ដដែល ព្រះអង្គបានឡាយព្រះហស្តលេខាលើសន្ធិសញ្ញាឯករាជ្យ ដែលប្រទេសបារាំងព្រមទទួលស្គាល់តាមផ្លូវច្បាប់ នូវឯករាជ្យរបស់ព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញាឆ្នាំ១៩៤៩នេះ លុបចោលនូវសន្ធិសញ្ញាអាណាព្យាបាលឆ្នាំ១៨៦៣ និងឆ្នាំ១៨៨៤។

ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៣ ដោយព្រះអង្គយល់ថាឯករាជ្យ ដែលប្រទេសបារាំងបានទទួលស្គាល់នៅឆ្នាំ១៩៤៩ ពុំទាន់មានលក្ខណៈពេញបរិបូណ៌ ដូច្នេះទើប **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានយាងបំពេញព្រះរាជបូជនីយកិច្ចទាមទារកេតនភណ្ឌឯករាជ្យ ១០០% ជូនជាតិមាតុភូមិ។

នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដោយស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យទាំងស្រុង ពីសាធារណរដ្ឋបារាំង។ ប្រជារាស្ត្រកម្ពុជាទូទាំងប្រទេសសូមថ្វាយព្រះកិត្តិនាមព្រះអង្គជា «**ព្រះមហាវីរបុរសជាតិ-ព្រះបិតាឯករាជ្យជាតិ**»។

នៅឆ្នាំ១៩៥៤ ព្រះអង្គបានបញ្ជូនព្រះរាជគណៈប្រតិភូ ជាព្រះរាជតំណាងរបស់ព្រះអង្គទៅចូលរួមនៅក្នុងសន្និសីទអន្តរជាតិ ស្តីពីបញ្ហាឥណ្ឌូចិន នៅទីក្រុងហ្សឺណែវ (Genève) ដែលមានប្រទេសកម្ពុជាចូលរួមក្នុងឋានៈជារដ្ឋឯករាជ្យ ឯកភាពជាតិ។

នៅថ្ងៃព្រហស្បតិ៍១០កើត ខែផល្គុន ឆ្នាំមមី ឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៥ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានដាក់រាជ្យថ្វាយ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សុរាម្រិត** ជាព្រះរាជបិតា។ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សុរាម្រិត** ព្រះអង្គ បានប្រទានចំពោះ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** នូវព្រះបរមងារជា «**សម្តេចព្រះឧបយុវរាជ នៃព្រះរាជាណាចក្រកម្ពុជា**»។

ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយម ដែលមានគណបក្សជាច្រើនចូលរួមក្នុងចលនានេះ។

ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៥**ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានចូលរួមក្នុងសន្និសីទកំពូល អាហ្វ្រិក-អាស៊ី លើកទី១ នៅទីក្រុងបាន់ឌុង

(Bandung) ប្រទេសឥណ្ឌូណេស៊ី ហើយនៅទីនោះ ព្រះអង្គបានប្រកាសពីនយោបាយអព្យាក្រឹតក្នុងឯករាជ្យទាំងស្រុង និងសន្តិសហវិជ្ជមាន នៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសទាំងអស់ ដោយមិនគិតពីមនោគមវិជ្ជាឡើយ។ ព្រះអង្គបានជួបជាលើកដំបូងជាមួយនឹងលោក ហ្សាវ៉ាហារឡាល់ នេរុ (Jawaharlal Nehru) នាយករដ្ឋមន្ត្រីឥណ្ឌា, លោក ហ្គាម៉ាល់ អាប់ដែល ណាស៊ែរ (Gamal Abdel Nasser) ប្រធានាធិបតីសាធារណរដ្ឋអារ៉ាប់រួមអេហ្ស៊ីប, លោក អាម៉េត ស៊ូការណូ (Ahamed Sukarno) ប្រធានាធិបតីឥណ្ឌូណេស៊ី, លោក ជូ អេនឡាយ (Zhou En Lai) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន។

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥ **ព្រះករុណា ព្រះចាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គ បានទទួលមហាជោគជ័យក្នុងការបោះឆ្នោតរដ្ឋសភា ដោយបានទទួលការគាំទ្រពីប្រជារាស្ត្រខ្មែរច្រើនលើសលប់។ ព្រះអង្គបានទទួលព្រះរាជឋានៈជានាយករដ្ឋមន្ត្រី ហើយក្នុងព្រះឋានៈជាប្រមុខ នៃប្រជារាស្ត្រខ្មែរ ព្រះអង្គបានបំពេញព្រះរាជកិច្ចដឹកនាំ ដើម្បីអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាជាទូទៅ នៅក្នុងគ្រប់វិស័យនៃការកសាងជាតិរបស់ព្រះអង្គ ជាពិសេសការលើកស្ទួយនារី ឲ្យមានសិទ្ធិស្មើភាពនឹងបុរសក្នុងការងារ។

ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៥៥ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ **ព្រះករុណា ព្រះចាទសម្តេច ព្រះនរោត្តម សីហនុ** ប្រទេសកម្ពុជាបានចូលជាសមាជិក នៃអង្គការសហប្រជាជាតិ។

នៅឆ្នាំ១៩៥៦ នៅ ប្រីយ៉ូនី (Brioni) នៃសាធារណរដ្ឋ សហព័ន្ធសង្គមនិយមយូហ្គោស្លាវី **ព្រះករុណា ព្រះចាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានក្លាយជាបិតាស្ថាបនិកទី៥ ចលនាមិនចូលបក្សសម្ព័ន្ធ ដោយបានឡាយព្រះហស្តលេខាលើធម្មនុញ្ញ នៃចលនាមិនចូលបក្សសម្ព័ន្ធបន្ទាប់ពីអ្នកផ្តួចផ្តើមគំនិតដ៏សំខាន់៤រូបទៀតៈលោក ហ្ស៊ូស៊ីប ប្រូស ទីតូ (Josip Broz Tito) ប្រធានាធិបតីយូហ្គោស្លាវី, លោក ហ្សាវ៉ាហារឡាល់ នេរុ (Jawaharlal Nehru) នាយករដ្ឋមន្ត្រីឥណ្ឌា លោក អាម៉េត ស៊ូការណូ (Ahmed Sukarno) ប្រធានាធិបតីឥណ្ឌូណេស៊ី និងលោក ហ្គាម៉ាល់ អាប់ដែល ណាស៊ែរ (Gamel Abdel Nasser) ប្រធានាធិបតីសាធារណរដ្ឋអារ៉ាប់រួមអេហ្ស៊ីប។

នៅខែកុម្ភៈ ឆ្នាំ១៩៥៦ **ព្រះករុណា ព្រះចាទសម្តេច ព្រះនរោត្តម សីហនុ** ក្នុងព្រះឋានៈជានាយករដ្ឋមន្ត្រី ព្រះអង្គបានយាងទៅបំពេញទស្សនកិច្ចជាផ្លូវរដ្ឋ នៅសាធារណរដ្ឋប្រជាមានិតចិន និងបានជួបជាមួយថ្នាក់ដឹកនាំចិនជាច្រើនរូប មានឯកឧត្តមប្រធាន ម៉ៅ សេទុង (Mao TseTung) ជាដើម។ ព្រះអង្គបានឡាយព្រះហស្តលេខាលើសេចក្តីប្រកាសរួមស្តីពីមិត្តភាពកម្ពុជា-ចិន។

នៅឆ្នាំ១៩៦០ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សុរាម្រិត** ទ្រង់សោយទិវង្គតពេលនោះ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** ត្រូវបានសមាជិករដ្ឋសភាខ្មែរ សម្រេចជាឯកច្ឆន្ទជ្រើសតាំងព្រះអង្គជា **ព្រះប្រមុខរដ្ឋ** នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងព្រះឋានៈនេះ ព្រះអង្គបានបន្តការដឹកនាំប្រជារាស្ត្រខ្មែរ ក្នុងព្រះរាជកិច្ចកសាងជាតិមាតុភូមិយ៉ាងសកម្មជាទីបំផុត។

ខែកញ្ញា ឆ្នាំ១៩៦០ នៅមហាសន្និបាតអង្គការសហប្រជាជាតិ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានលើកឡើងនូវផែនការបង្កើតអាស៊ីអាគ្នេយ៍ជាតំបន់អព្យាក្រឹត រវាងប្លុកមហាអំណាចទាំងពីរ គឺលោកសេរី និងលោកសង្គមនិយម។

នៅខែឧសភា ឆ្នាំ១៩៦១ តាមព្រះរាជតម្រិះផ្ដួចផ្ដើមរបស់ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** សន្និសីទអន្តរជាតិមួយត្រូវបានបង្កើតឡើង នៅទីក្រុងហ្សឺណែវ (Genève) ដើម្បីដោះស្រាយទំនាស់រវាងភាគីទាំង ៣ នៅប្រទេសឡាវ។

ចាប់ពីខែឧសភា ឆ្នាំ១៩៦១ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានបំពេញព្រះរាជបេសកកម្មនយោបាយការទូត និងផ្លូវច្បាប់ ដើម្បីទាមទារប្រាសាទព្រះវិហារជាសម្បត្តិវប្បធម៌បេតិកភ័ណ្ឌជាតិខ្មែរ ពីប្រទេសថៃមកវិញ ដោយតុលាការក្រុង ឡាអេ (La Haye) បានសម្រេចប្រគល់មកជូនព្រះរាជាណាចក្រកម្ពុជាវិញ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២។

នៅខែវិច្ឆិកា ឆ្នាំ១៩៦១ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានយាងចូលរួមក្នុងសន្និសីទកំពូលលើកទី១ នៃចលនាមិនចូលបក្សសម្ព័ន្ធនៅ បែលក្រាដ (Belgrade) នៃប្រទេសយូហ្គោស្លាវី ដែលមាន ២៥ ប្រទេស ចូលរួម។ នៅទីនោះព្រះអង្គបានថ្កោលទោសចំពោះអំពើរបស់ពួកអាណានិគមនិយម ចក្រពត្តិនិយម និងការប្រកាន់ពូជសាសន៍។

នៅខែមិថុនា ឆ្នាំ១៩៦៤ លោកឧត្តមសេនីយ៍ សាល ដឺ ហ្គោល (Charles de Gaulle) ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង បានរៀបចំបដិសណ្ឋារកិច្ចជាឱឡារិកថ្វាយ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** នៅទីក្រុងប៉ារីស។ លោកប្រធានាធិបតីបានទទួលដោយស្មោះសរនូវសំណើរបស់ភាគីកម្ពុជា ស្ដីពីការទទួលស្គាល់អព្យាក្រឹតភាព នៃព្រះរាជាណាចក្រកម្ពុជា។

នៅចុងខែសីហា និងដើមខែកញ្ញា ឆ្នាំ១៩៦៦ **ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ** បានរៀបចំបដិសណ្ឋារកិច្ចទទួលជាឱឡារិក លោកឧត្តមសេនីយ៍ សាល ដឺ ហ្គោល (Charles de Gaulle) ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ដែលបានមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋ

នៅព្រះរាជាណាចក្រកម្ពុជា។ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៦៦ នៅក្នុងសុន្ទរកថា ដែលថ្លែងនៅពហុកីឡដ្ឋានជាតិអូឡាំពិកភ្នំពេញ លោកប្រធានាធិបតីបានគាំទ្រព្រះរាជាណាចក្រកម្ពុជា ដែលការពារឯករាជ្យ បូរណភាពទឹកដី អព្យាក្រឹត សន្តិភាពនៃខ្លួន។

ពីថ្ងៃទី២៦ ខែវិច្ឆិកា ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៦៦ **ព្រះករុណា ព្រះចៅសម្តេច ព្រះនរោត្តម សីហនុ** បានយាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងឱកាសព្រះរាជពិធីបើក និងបិទការប្រកួតកីឡា GANEFO អាស៊ី លើកទី១ នៅរាជធានីភ្នំពេញ។

ក្រោមព្រះរាជកិច្ចដឹកនាំរបស់ **ព្រះករុណា ព្រះចៅសម្តេច ព្រះនរោត្តម សីហនុ** ក្នុងសម័យសង្គមរាស្ត្រនិយម ដែលប្រជារាស្ត្រខ្មែរបានថ្វាយព្រះនាមព្រះអង្គថាជា «**ព្រះបិតាឯករាជ្យជាតិ-ព្រះបិតាសិក្សាធិការជាតិ-ព្រះបិតាកីឡាជាតិ-ព្រះបិតាស្ថាបនាជាតិ**» សមិទ្ធផលនានាជាច្រើន បានត្រូវកសាងឡើង និងប្រារព្ធព្រះរាជពិធីសម្ពោធជាបន្តបន្ទាប់សម្រាប់ប្រជារាស្ត្រប្រើប្រាស់នៅតាមបណ្តាខេត្ត-ក្រុងនានា ជាពិសេសមានសមិទ្ធផលធំៗ ដូចជា:

-វិមានឯករាជ្យ

-វិមានរដ្ឋចំការមន

-ចំណតអាកាសយានដ្ឋាន អន្តរជាតិពោធិចិនតុង

-ចំណតអាកាសយានដ្ឋាន សៀមរាប

-ចំណតអាកាសយានដ្ឋាន បែកចាន ខេត្តបាត់ដំបង

-ផ្លូវជាតិលេខ៤ ភ្នំពេញ - ក្រុងព្រះសីហនុ

-ផ្លូវដែក ក្រុងភ្នំពេញ - ក្រុងព្រះសីហនុ

-កំពង់ផែអន្តរជាតិ ក្រុងព្រះសីហនុ

-សណ្ឋាគារ «ឯករាជ្យ» ក្រុងព្រះសីហនុ

-សាលមហោស្រពជាតិ «**ព្រះសុរាម្រិត**» ភ្នំពេញ

-សាលសន្និសីទ «ចតុមុខ»

-ពហុកីឡាដ្ឋានជាតិអូឡាំពិក ភ្នំពេញ

-ស្ពានព្រះមុនីវង្សទី ២

-ស្ពាន «សង្គមរាស្ត្រនិយម» ឆ្លងកាត់ទន្លេសាប

-សាកលវិទ្យាល័យ «សង្គមរាស្ត្រនិយម» ភ្នំពេញ (Université «Sangkum Reastr Niyum»)

-សាកលវិទ្យាល័យ ភូមិន្ទបច្ចេកទេស (Université Technique Royale)

-សាលាភូមិន្ទរដ្ឋបាល (Ecole Royale d' Administration)

-មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (Faculté de Droit et des Sciences Economiques)

-មហាវិទ្យាល័យ គរុកោសល្យ (Faculté de Pédagogie)

-ពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ (Université Bouddhique Preah Sihanouk Raj)

-មហាវិទ្យាល័យ សិល្បៈស្ថាបនា (Faculté du Génie Civil)

-មហាវិទ្យាល័យ សិល្បៈ និងមុខរបរ (Faculté des Arts et Métiers)

-សាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ (Université Royale des Beaux Arts)

-សាកលវិទ្យាល័យ ភូមិន្ទក្សេត្រសាស្ត្រ (Université Royale des Sciences Agronomiques)

-សាកលវិទ្យាល័យ ភូមិន្ទ កំពង់ចាម (Université Royale de Kompong Cham)

-សាកលវិទ្យាល័យ ភូមិន្ទ បាត់ដំបង (Université Royale de Battambang)

-សាកលវិទ្យាល័យ ភូមិន្ទ តាកែវ-កំពត (Université Royale Takeo-Kampot)

-រោងភាពយន្តរដ្ឋ (Cinéma d' Etat)

-ស្ថានីយ៍ទូរទស្សន៍ ខេមរភូមិន្ទ (Station de la Télévision Royale)

-មន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត (Hôpital de l' Amitié Khmèro-Soviétique)

-រោងចក្រ ចម្រាញ់ប្រេងកាត ក្រុងព្រះសីហនុ (Raffinerie de Pétrole de Sihanouk ville)

-រោងចក្រ ស្រាបៀ ក្រុងព្រះសីហនុ (Brasserie de Sihanouk ville)

-រោងចក្រ «ព្រះនរោត្តម» ដំឡើងត្រាក់ទ័រ និងរថយន្តធំក្រុងព្រះសីហនុ (Usine «Preah Norodom» de Montage de Tracteurs et de Camions Sihanouk ville)

-រោងចក្រ ស្ករស កំពង់ត្រាំ ខេត្តកំពង់ស្ពឺ (Raffinerie de Sucre)

-រោងចក្រ វាយនភ័ណ្ឌ ខេត្តកំពង់ចាម (Usine de Textiles à Kompong Cham)

-រោងចក្រ វាយនភ័ណ្ឌ ខេត្តបាត់ដំបង (Usine de Textiles à Battambang)

-រោងចក្រ បាវ ក្រចៅជូនទាវ ខេត្តបាត់ដំបង (Usine de Tissage de Sacs en Jute)

-រោងចក្រ ស៊ីម៉ង់ត៍ ចក្រីទីង ខេត្តកំពត (Cimenterie de Chakreyting)

-រោងចក្រ កែវ ជើងឯក រាជធានីភ្នំពេញ (Verrerie d' Etat)

-រោងចក្រ ក្តារបន្ទះ ដីឥដ្ឋ ខេត្តកណ្តាល (Usine de Contre-Plaqués)

-រោងចក្រ ក្រដាស ឆ្លូង ខេត្តក្រចេះ (Usine de Papier)

-រោងចក្រ ជីហ្វូសស្វាត ទូកមាស ខេត្តកំពត (Usine de Phosphates)
-រោងចក្រ កង់ឡាន តាខ្មៅ ខេត្តកណ្ដាល (Usine d´Etat de Phneumatiques)
-រោងចក្រ ត្រីខប្រអប់ ខេត្តកោះកុង (Conserverie de Poissons)
-រោងចក្រ ផលិតជ័រកៅស៊ូជប់ ខេត្តកំពង់ចាម (Usine de Latex à chup)
-រោងចក្រ វារីអគ្គិសនី គីរីរម្យ ខេត្តកំពង់ស្ពឺ (Usine Hydro-électrique de Kirirum)

និងសមិទ្ធផលនានាជាច្រើនទៀត នៅតាមបណ្ដាស្រុក - ខេត្ត - ក្រុង ដូចជាសាលារៀន មន្ទីរពេទ្យ ទំនប់ទឹក ស្រះទឹក ប្រឡាយ ផ្លូវថ្នល់ ស្ពានជាដើម។ល។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងពេលដែលព្រះអង្គកំពុងបំពេញព្រះរាជទស្សនកិច្ចជាផ្លូវការ នៅសហភាពសូវៀត **ព្រះករុណា ព្រះចាទសម្ដេចព្រះនរោត្ដម សីហនុ** ត្រូវបានទទួលរងគ្រោះដោយរដ្ឋប្រហារមិនស្របច្បាប់មួយនៅភ្នំពេញ គឺជារដ្ឋប្រហារយោធា ដែលមាន លន់ នល់ ជាមេក្លោង។ សាធារណរដ្ឋខ្មែររបស់លន់ នល់ ត្រូវបានបង្កើតឡើងនៅខែតុលា ឆ្នាំ១៩៧០។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ **ព្រះករុណា ព្រះចាទសម្ដេច ព្រះនរោត្ដម សីហនុ** ព្រះអង្គជាព្រះប្រធានចលនាតស៊ូកម្ពុជា «**រណសិរ្សរួបរួមជាតិកម្ពុជា**» (FUNC) ព្រមជាមួយនោះក៏មានបង្កើតនូវរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK)។

នៅខែមេសា ឆ្នាំ១៩៧០ នៅកង់តុង (Canton) សាធារណរដ្ឋប្រជាមានិតចិន ព្រះអង្គជាអ្នកផ្ដួចផ្ដើម នៃសន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិន ដែលនៅក្នុងនោះមានការចូលរួមដោយអ្នកដឹកនាំពីប្រទេសកម្ពុជា ពីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដឹកនាំដោយលោក នាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង (Pham Van Dong) ពីរណសិរ្សជាតិរំដោះវៀតណាមខាងត្បូង ដឹកនាំដោយលោកង្វៀង ហ៊ីវ ថ (Nguyen Huu Tho) និងពី ណេវ ឡាវ ហាក់សាត (Neo Lao Haksat) ដឹកនាំដោយ ព្រះអង្គម្ចាស់ប្រធានសុផានុវង្ស (Suphanouvong)។ ភាគីសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង និងភាគី ណេវ ឡាវ ហាក់សាត (Neo Lao Haksat) បានប្រកាសជាឱឡារិកថា ប្រទេសរបស់ខ្លួនទទួលស្គាល់ និងគោរពជាដរាបបូរណភាពទឹកដីក្នុងព្រំដែនបច្ចុប្បន្នរបស់កម្ពុជា។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជនរំដោះជាតិ នៃរណសិរ្សរួបរួមជាតិកម្ពុជា (FUNC) ដណ្ដើមបានជ័យជំនះទាំងស្រុងនៅកម្ពុជា។ «កម្ពុជាប្រជាធិបតេយ្យ» ត្រូវបានបង្កើតឡើង ដែលមាន **ព្រះករុណា ព្រះចាទសម្ដេច ព្រះនរោត្ដម សីហនុ** ជាព្រះប្រធាន។ ប៉ុន្តែនៅខែមេសា ឆ្នាំ១៩៧៦ ព្រះអង្គបានសព្វព្រះរាជហឫទ័យ លាលែងមុខងារជាព្រះប្រធាន នៃកម្ពុជា

ប្រជាធិបតេយ្យនេះ ហើយត្រូវពួកខ្មែរក្រហមឃុំឃាំង **ព្រះអង្គ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រមទាំងផ្ញើគុតព្រះរាជបុត្រា បុត្រី មួយចំនួនផង។

នៅឆ្នាំ១៩៨២ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ត្រូវបានជ្រើសតាំងជាព្រះប្រធានកម្ពុជាប្រជាធិបតេយ្យជាលើកទី២។

ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៩០ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គជាព្រះប្រធាន នៃចលនាតស៊ូជាតិកម្ពុជា (CNR)។

ចាប់តាំងពីឆ្នាំ១៩៨៧ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានខិតខំអស់ពីព្រះកាយពល ដើម្បីបង្រួបបង្រួមភាគីជម្លោះកម្ពុជាទាំងអស់ រិះរកនូវដំណោះស្រាយនយោបាយសមស្រប បញ្ចប់ជម្លោះនៅកម្ពុជា។ ព្រះអង្គតែងតែប្រទានចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងគណៈប្រតិភូ នៃរដ្ឋកម្ពុជាចូលក្រាបថ្វាយបង្គំគាល់ជាបន្តបន្ទាប់នៅប្រទេសបារាំង:

-ពីថ្ងៃទី០២ ដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៨៧ ជំនួបជាលើកទី១នៅ Fère-en-Tardenois។

-ពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៨៨ ជំនួបជាលើកទី២ នៅ Saint-Germain-en-Laye។

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩១ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** បានទទួលពីមេដឹកនាំ នៃកម្ពុជាទាំង ៤ភាគី ដើម្បីប្រកាសជាឱឡារិកនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយទទួលស្គាល់ការបញ្ឈប់ជាបណ្តោះអាសន្ននូវការបាញ់គ្នា នៅប្រទេសកម្ពុជាទាំងមូល និងបញ្ឈប់ការផ្តល់ជំនួយយោធា «អាវុធ...» ពីប្រទេសដទៃដល់កងទ័ពកម្ពុជាទាំង ៤ភាគី។ ទីក្រុងភ្នំពេញ ត្រូវបានជ្រើសដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC) ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ជាទីស្នាក់ការផ្លូវការអចិន្ត្រៃយ៍ និងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (SNC)។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩១ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានយាងចាកចេញពីប្រធាននៃកម្ពុជាប្រជាធិបតេយ្យ និងចលនាតស៊ូជាតិកម្ពុជា (CNR) ដើម្បីដាក់ព្រះកាយព្រះអង្គនៅពីលើភាគី និងទស្សនៈនយោបាយកម្ពុជានានា។ ព្រះអង្គត្រូវបានសមាជិកទាំង១១ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC) ជ្រើសតាំងជាឯកច្ឆន្ទជាព្រះប្រធាន«អព្យាក្រឹត» នៃក្រុមប្រឹក្សានេះ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានឡាយព្រះហស្តលេខា«លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា» ជាមួយសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ១១ រូបទៀត ជាមួយតំណាងរដ្ឋាភិបាល ១៨ប្រទេស និងជាមួយលោកអគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ។

នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** យាងនិវត្តមកកាន់រាជធានីភ្នំពេញវិញ ប្រកបដោយជោគជ័យ និងសុវត្ថិភាព។ ក្រោយពីមាតុ-ភូមិនិវត្តន៍របស់ព្រះអង្គ រដ្ឋាភិបាល នៃរដ្ឋកម្ពុជាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ជាប្រធានគណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលមាន សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាប្រធានគណបក្ស, គណបក្សប្រជាធិបតេយ្យសេរីនិយម ព្រះពុទ្ធសាសនា ដែលមានសម្តេចបវរសេដ្ឋា សឺន សាន ជាប្រធានគណបក្ស និងភាគីកម្ពុជាប្រជាធិបតេយ្យ ដែលមានលោក ខៀវ សំផន ជាប្រធាន បានប្រកាសជាបន្តបន្ទាប់ជាផ្លូវការ និងជាលាយលក្ខណ៍អក្សរថា **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** នៅតែជាព្រះប្រមុខរដ្ឋ ពេញលក្ខណៈច្បាប់ នៃប្រទេសកម្ពុជាទាំងមូល និងម្យ៉ាងទៀត **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ជាផ្លូវការនៅតែរក្សាទុកតួនាទីជាព្រះប្រមុខរដ្ឋ រហូតដល់មានការបោះឆ្នោតនៅកម្ពុជាឆ្នាំ១៩៩៣។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** បានឡាយព្រះហស្តលេខា លើព្រះរាជក្រម ប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ នូវរដ្ឋធម្មនុញ្ញថ្មី នៃព្រះរាជាណាចក្រកម្ពុជា ដែលសភាធម្មនុញ្ញកម្ពុជាបានអនុម័ត។

នៅថ្ងៃសុក្រ ៩កើត ខែភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស.២៥៣៧ ត្រូវនឹងថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ត្រូវបានក្រុមប្រឹក្សារាជសម្បត្តិ ជ្រើសតាំងជា **ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មហាមិទ្ទិញមហាជនមួយ ក៏ត្រូវបានរៀបចំឡើង ដោយមានមហាជនយ៉ាងច្រើនកុះករចូលរួម ដើម្បីសម្តែងមនោសញ្ចេតនា អបអរ គាំទ្រ ស្វាគមន៍ ចំពោះរដ្ឋធម្មនុញ្ញថ្មី និងព្រះឋានៈព្រះអង្គជា «**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា**»។

**ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានបំពេញព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តមជាទីបំផុត ក្នុងការបង្រួបបង្រួម ផ្សះផ្សាជាតិ តាំងពីដើមរហូតមក។ ព្រះអង្គបានធ្វើឲ្យចេញជារូបរាង រាជរដ្ឋាភិបាលចម្រុះ ដែលមានសហនាយករដ្ឋមន្ត្រី នៅឆ្នាំ១៩៩៣ ហើយជាពិសេសព្រះអង្គបានបំពេញព្រះរាជកិច្ច ធ្វើឲ្យថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងគណ-បក្សហ្វ៊ុនស៊ិនប៉ិច ចុះហត្ថលេខាលើសេចក្តីប្រកាសរួម អំពីគោលការណ៍សហប្រតិបត្តិការ ដែល

បានសម្រេចក្នុងកិច្ចប្រជុំកំពូល ក្រោមព្រះរាជាធិបតីភាព នៃព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅមហាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង ថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨។ ប្រជារាស្ត្រកម្ពុជាទូទាំងព្រះរាជាណាចក្រកម្ពុជា សូមថ្វាយព្រះរាជអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះរាជកិច្ច ព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តមនេះ។

នៅថ្ងៃ១៥កើត ពេញបូណ៌មី ខែមិគសិរ ឆ្នាំមមី ចត្វាស័ក ព.ស. ២៥៤៦ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ ព្រះអង្គបានយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងព្រះរាជពិធីដង្ហែព្រះសារីរិកធាតុពីព្រះសក្យមុនីចេតិយ មុខស្ថានីយ៍រាជាយស្ម័យយានរាជធានីភ្នំពេញ ឆ្ពោះទៅព្រះមហាសក្យមុនីចេតិយថ្មី នៅភ្នំអង្គរស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល ទៅតាមព្រះរាជតម្រិះរបស់ព្រះអង្គ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩១ នៅក្នុងឱកាសមហាមិទ្ទិញ នៅមុខព្រះបរមរាជវាំង។

នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១១ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គយាងជាព្រះរាជាធិបតីភាព ក្នុងអង្គមហាមិទ្ទិញមហាជនអបអរសាទរ ព្រះរាជពិធីបុណ្យថ្វាយព្រះពរ និងចម្រើនព្រះជន្មយាងចូល៩០ ព្រះវស្សា និងខួបលើកទី២០ឆ្នាំ នៃការយាងធ្វើមាតុភូមិនិវត្តន៍មកកាន់កម្ពុជា នៅខាងមុខព្រះទីនាំងចន្ទឆាយា មុខព្រះបរមរាជវាំង ដែលជាការបង្ហាញព្រះភក្ត្រចុងក្រោយ ចំពោះកូនចៅ ចៅទួត ចៅលួត របស់ព្រះអង្គ។ នៅក្នុងឱកាសដ៏មហោឡារិកនោះ **ព្រះករុណា ព្រះមហាវីរក្សត្រ** ព្រះអង្គមានព្រះរាជឱង្ការដ៏ខ្ពង់ខ្ពស់ ដែលជាព្រះរាជបណ្ដាំចុងក្រោយបង្អស់របស់ព្រះអង្គថា ព្រះអង្គឈប់យាងចេញទៅបរទេស ឆ្ងាយពីប្រជារាស្ត្រកម្ពុជា ជាកូនចៅ ចៅទួត ចៅលួត របស់ព្រះអង្គទៀតហើយ ព្រះអង្គនឹងគង់ប្រថាប់ជាដរាប នៅជាមួយប្រជារាស្ត្រជាកូនចៅ ចៅទួត ចៅលួត រហូតដល់អស់ព្រះជន្ម។ ព្រះអង្គបានមានព្រះរាជបន្ទូលផ្ដែផ្ដាំថា "សូមបងប្អូន ប្រជារាស្ត្រ កូនចៅ ចៅទួត ចៅលួត សាមគ្គីជាធ្លុងមួយ រួមរស់ជាមួយគ្នា ដោយមានសម្ដេច ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាល ដែលបង្ហាញឲ្យពិភពលោកឃើញថា យើងរួបរួមគ្នាល្អណាស់"។

**ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និងសម្ដេច**ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** បានមានព្រះរាជបន្ទូលបញ្ជាក់ហើយ បញ្ជាក់ទៀតថា ព្រះអង្គបានសម្រេចជាស្ថាពរថា មិនចេញពីប្រទេសទេ គឺស្ថិតនៅជាដរាបជាមួយបងប្អូន កូនចៅ នៅក្នុងប្រទេសកម្ពុជាយើង ។

ព្រះអង្គបានមានព្រះរាជបន្ទូលថា ពេលព្រះអង្គគង់នៅជាដរាប ជាមួយកូនចៅ ចៅទួត ចៅលួត ព្រះអង្គមានសុភមង្គលណាស់ ។ តាមព្រះរាជឱង្ការនេះ បញ្ជាក់ច្បាស់ថា **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ**នឹងគង់នៅជាអមតៈជាមួយកូនចៅ ចៅទួត ចៅលួត របស់ព្រះអង្គ។ ព្រះអង្គសរសើរ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សម្ដេចនាយករដ្ឋមន្ត្រី សម្ដេចប្រធានព្រឹទ្ធសភា សម្ដេចប្រធានរដ្ឋសភា និងប្រជារាស្ត្រ ដែលបានកសាងប្រទេសជាតិ

បង្ហាញឲ្យពិភពលោកឃើញច្បាស់ថា កម្ពុជាបានលូតលាស់គ្មានឈប់ឈរ បានកសាងជាតិ ជួយជនរួមជាតិ ពិសេសជួយប្រជារាស្ត្រក្រីក្រជាដើម ។ ព្រះអង្គលើកសរសើរទៀតថា “យើងរួបរួមគ្នាល្អណាស់ ក្នុងការដោះស្រាយបញ្ហាជាតិ។ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និងរាជរដ្ឋាភិបាល កងយោធពលខេមរភូមិន្ទ ប្រជាជាតិទាំងអស់ ពួតដៃគ្នាកសាងជាតិ ដើម្បីកម្ពុជាប្រាសចាកជាដាច់ខាត ពីភាពទន់ខ្សោយ ឈានទៅកាន់ភាពរុងរឿង ក្នុងពិភពលោក។ ទាំងនេះបង្ហាញពិភពលោកថា កម្ពុជារួបរួមគ្នាល្អណាស់ ក្នុងសន្តិភាព ឯករាជ្យ កសាងជាតិគ្មានឈប់ឈរ ទោះបីព្រះអង្គយាងចូលនិវត្តន៍ហើយក៏ដោយ ក៏នៅតែបន្តកសាងជាតិ រួបរួមជាមួយរាជរដ្ឋាភិបាល ដែលនេះជាលើកទីមួយហើយ ដែលកម្ពុជាយើងរួបរួមគ្នាជាធ្លុងមួយ គ្មានអ្នកណាបំបែកបាន”។

**ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ជាទីសក្ការៈជា **ព្រះមហាវីរក្សត្រ** មួយព្រះអង្គ ដែលតែងតែប្រកាន់ខ្ជាប់នូវព្រះរាជកិច្ច ប្រកបដោយព្រះព្រហ្មវិហារធម៌ ដ៏ឧត្តុង្គឧត្តមចំពោះប្រជានុរាស្ត្រជាកូនចៅ ចៅទួត ចៅលួត របស់ព្រះអង្គនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ តាំងពីដើមរៀងរហូតមកដល់បច្ចុប្បន្ន ព្រះអង្គតែងតែបំពេញព្រះរាជសកម្មភាពសង្គមកិច្ច ដូចជាការកសាងព្រះវិហារ កុដិ សាលាបុណ្យ សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង ផ្លូវថ្នល់ ទំនប់ទឹក ប្រឡាយ អណ្តូងទឹក ស្រះទឹក សម្រាប់ប្រគេនព្រះសង្ឃ និងជូនប្រជារាស្ត្រ។ ព្រះអង្គបានប្រោសព្រះរាជទាន និងបន្តនូវការប្រោសព្រះរាជទាន (រៀងរាល់សប្តាហ៍) ព្រះរាជអំណោយដល់ប្រជានុរាស្ត្រទីទ័លក្រ និងមានជីវភាពខ្វះខាតខ្លាំង។

ព្រះរាជសកម្មភាពដ៏ថ្លៃថ្លាខាងលើនេះ បានបង្ហាញឲ្យឃើញនូវសច្ចធម៌ នៃទសពិធរាជធម៌ របស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ជាទីសក្ការៈ ដែលព្រះអង្គបានប្រោសព្រះរាជទានដល់ប្រជារាស្ត្រកម្ពុជា ដោយមិនប្រកាន់ជាតិកំណើត ជំនឿសាសនា ពណ៌សម្បុរឡើយ។ ដោយសារសច្ចភាពនេះហើយ ទើបគ្រប់គណបក្សនយោបាយ និងប្រជារាស្ត្រទូទាំងប្រទេសបានគាំទ្រដោយឥតសំចៃថ្វាយព្រះអង្គ ចំពោះការយាងគ្រងរាជសម្បត្តិសារជាថ្មីនៅឆ្នាំ១៩៩៣ ហើយដែលពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពិភពលោកកន្លងមក។ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គជាមហាពុទ្ធសាសនូបត្ថម្ភកៈដ៏ឧត្តុង្គឧត្តមថ្លៃថ្លាបំផុត ជ្រះថ្លានឹងព្រះពុទ្ធសាសនា ប្រតិបត្តិតាមពុទ្ធោវាទ ដោយសទ្ធាបរិសុទ្ធ ក្នុងព្រះទ័យស្ថាបនារក្សាការពារ ស្រឡាញ់សន្តិភាពយ៉ាងមោះមុត ទាំងនៅក្នុងប្រទេស ទាំងនៅលើសកលលោកទាំងមូល ជាពិសេស ព្រះអង្គបាននាំមកនូវសន្តិភាព សេចក្តីសុខស្ងប់ដ៏បរិសុទ្ធ និងវិបុលភាព ជូនមាតុភូមិ និងប្រជាជនកម្ពុជា។ ដោយហេតុនេះហើយ បានជាកាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១២ សន្និសីទកំពូល នៃព្រះពុទ្ធសាសនាពិភពលោក ដែលមានព្រះតេជព្រះគុណបណ្ឌិត Most Ven. Dr Kyuse Enshinjoh ជាប្រធាន មានទីស្នាក់ការនៅប្រទេសជប៉ុនបានថ្វាយព្រះគោរមងារព្រះអង្គ ជា «**ព្រះរាជឧត្តមបិតា នៃពុទ្ធសាសនិកពិភពលោក**» (Supreme Royal Father

of The World Buddhism)។

នៅថ្ងៃ១៥រោច ខែកត្តិក ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង០១.២០នាទី រំលងអាធ្រាត្រ **ព្រះករុណា ព្រះមហាវីរក្សត្រ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ** ព្រះអង្គបានយាងចូលព្រះទិវង្គត ដោយព្រះជរាពាធ ក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា នៅមន្ទីរពេទ្យទីក្រុងប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន។

គណៈកម្មាធិការរៀបចំព្រះរាជពិធីបុណ្យព្រះបរមសព **ព្រះករុណា ព្រះមហាវីរក្សត្រ** ត្រូវបានបង្កើតឡើងជាបន្ទាន់ដោយមានសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ជាប្រធាន សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ជាអនុប្រធាន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាអនុប្រធានប្រចាំការ សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឆ្លារ គង់ សំអុល ជាអនុប្រធានអចិន្ត្រៃយ៍ ឯកឧត្តមជាឧបនាយករដ្ឋមន្ត្រី ជាច្រើនរូបទៀត ជាអនុប្រធាន និងមានឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ព្រមទាំងឯកឧត្តមអភិបាល រាជធានី-ខេត្ត ទាំងអស់ជាសមាជិក។

នៅថ្ងៃ២កើត ខែអស្សុជ ត្រូវនឹងថ្ងៃទី១៧ ខែ ឆ្នាំ ដដែល ព្រះបរមសពត្រូវបានដង្ហែមកកាន់មាតុប្រទេសវិញ តាមព្រះទីនាំងយន្តហោះពិសេស។ ក្បួនរាជរថដង្ហែព្រះបរមសពពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ មកកាន់ព្រះបរមរាជវាំង ដោយមានប្រជាជនប្រមាណ ១២០ ម៉ឺននាក់ ចូលរួមកាន់ព្រះរាជមរណទុក្ខ ទទួលព្រះបរមសពនៅតាមដងវិថីនានា។

នៅថ្ងៃ១១ រោច ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១២ វេលាម៉ោង១៣.០០ សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ និងសម្តេចព្រះសង្ឃ ១០ព្រះអង្គ បានប្រជុំថ្វាយព្រះបរមបច្ឆាមរណនាម ជា «**ព្រះបរមរតនកោដ្ឋ**» ថ្វាយព្រះបរមសព **ព្រះករុណា ព្រះមហាវីរក្សត្រ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** បានសព្វព្រះរាជហឫទ័យឡាយព្រះរាជក្រឹត្យថ្វាយព្រះបរមបច្ឆាមរណនាមនេះនៅក្នុងថ្ងៃដដែល។

នៅថ្ងៃអាទិត្យទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅប្រទេសជប៉ុន អង្គការសន្និសីទកំពូល នៃពុទ្ធសាសនាពិភពលោក ដែលមានព្រះតេជគុណបណ្ឌិត Most Ven. Dr. Kyuse Enshinjoh ជាប្រធាន បានប្រារព្ធ ធ្វើពិធីបុណ្យថ្វាយព្រះរាជកុសល ដ៏អធិកអធមមួយ ឧទ្ទិសថ្វាយព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះចាទសម្តេច ព្រះនរោត្តម សីហនុ «ព្រះបរមរតនកោដ្ឋ»** ដែលនៅក្នុងឱកាសដ៏ប្រពៃនោះ**ព្រះករុណា ព្រះចាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** និងសម្តេច **ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** បានចាត់បញ្ជូន សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ជាព្រះរាជតំណាងទៅចូលរួម។

នៅថ្ងៃ១៥កើត ពេញបូណ៌មី ខែកត្តិក ឆ្នាំរោង ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២

ក្រោមព្រះរាជាធិបតីភាពរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** និងសម្តេចព្រះមហាក្សត្រី **ព្រះវររាជមាតាជាតិខ្មែរ** សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ និងសម្តេចព្រះសង្ឃ ១០ព្រះអង្គ ដោយមានការអញ្ជើញចូលរួមរបស់សម្តេចអគ្គមហាពញាចក្រីហេង សំរិន ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឪ្ការ គង់ សំអុល បានប្រារព្ធព្រះរាជពិធីថ្វាយជាផ្លូវការ ចំពោះព្រះបរមសពនូវ ព្រះបរមបច្ឆាមរណនាមជា «**ព្រះបរមរតនកោដ្ឋ**»។

ប្រការដែលគួរឲ្យកត់សម្គាល់នោះគឺ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គបានប្រសូត (ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២) បានឡើងគ្រងព្រះបរមរាជសម្បត្តិ (លើកទី១ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៤១) និងបានយាងចូលព្រះទិវង្គត (ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២) នៅក្នុងខែតែមួយគឺ ខែតុលា ខុសតែថ្ងៃប៉ុណ្ណោះ។

**ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះអង្គជា **ព្រះមហាវីរក្សត្រ** ដ៏ឆ្នើមបំផុត ក្នុងមួយព្រះជន្មវស្សាព្រះអង្គ បានបូជាព្រះកាយពល ព្រះបញ្ញាញាណ ក្នុងព្រះរាជកិច្ចដ៏ឧត្តុង្គឧត្តម ថែរក្សាបូរណភាពទឹកដី ការពារព្រះនគរ ទ្រទ្រង់ព្រះសាសនាឲ្យបានគង់វង្ស និងរីកចម្រើនរុងរឿង សម្បូណ៌សប្បាយ មានកេរ្តិ៍ឈ្មោះល្បីរន្ទឺ សុសសាយទូទាំងពិភពលោក តាំងពីដើមរហូតមកដល់បច្ចុប្បន្នកាល។

បានក្រាបបង្គំទូលថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង**
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
និងសម្តេច **ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
និងបានទទួលព្រះរាជទានព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២

បានជម្រាបជូន និងបានទទួលការឯកភាពដ៏ខ្ពង់ខ្ពស់
ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៣

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឪ្ការ **គង់ សំអុល**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង


1922
2012
ព្រះចៅ
ក្រុង
កម្ពុជា